បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
លេខ : ៧៤០៤ .ប.ក.ទ.ក

# សេចក្តីណែនាំ
## ស្តីពី
## ការគ្រប់គ្រងតម្លៃដើមនៃសេវាទូរស័ព្ទចល័ត អចល័ត និងតម្លៃតភ្ជាប់បណ្តាញរវាងប្រតិបត្តិករទូរស័ព្ទមួយ ទៅប្រតិបត្តិករទូរស័ព្ទមួយទៀត

## បញ្ញត្តិករទូរគមនាគមន៍កម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១២/១៧៥ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១២/២០៦ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ស្តីពីការតែងតាំងមន្ត្រីរាជការចំនួន ៤រូប នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- លិខិតលេខ ២០៦៥ សជណ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីសំណើសុំនិរាករណ៍ប្រកាសអន្តរក្រសួងលេខ ២៣២ ស.ហ.វ.-បទ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ របស់ទីស្តីការគណៈ-រដ្ឋមន្ត្រី។

## សម្រេច

### ប្រការ ១. គោលបំណង

សេចក្តីណែនាំនេះ មានគោលបំណងគ្រប់គ្រងតម្លៃដើមនៃសេវាទូរស័ព្ទចល័ត អចល័ត និង តម្លៃតភ្ជាប់បណ្តាញរវាងប្រតិបត្តិករទូរស័ព្ទមួយទៅប្រតិបត្តិករទូរស័ព្ទមួយទៀត។

### ប្រការ ២. គោលដៅ



កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
(ក្នុងបរិវេណក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh

សេចក្តីណែនាំនេះ មានគោលដៅបង្កើតលក្ខខណ្ឌសមស្រប ដើម្បីធានាស្ថេរភាព និងរក្សា សុខភាពហិរញ្ញវត្ថុរបស់វិនិយោគិន ព្រមទាំងការប្រកួតប្រជែងដោយសេរី និងស្មោះត្រង់ របស់ប្រតិបត្តិករ ទូរគមនាគមន៍ទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៣. វិសាលភាព

សេចក្តីណែនាំនេះ មានវិសាភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ដែលកំពុងមានប្រតិបត្តិការ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤. និយមន័យ

បច្ចេកស័ព្ទទាំងឡាយដែលប្រើក្នុងសេចក្តីណែនាំនេះ មានន័យដូចតទៅ៖

- **បញ្ញត្តិករ (Regulator)**៖ គឺជាបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ដែលជានីតិបុគ្គលនៃនីតិសាធារណៈ និងបានទទួលសិទ្ធិពីរាជរដ្ឋាភិបាល មានស្វ័យភាពក្នុងការងារត្រួតពិនិត្យ និងគ្រប់គ្រងខាងផ្លូវបច្ចេក-ទេស និងរដ្ឋបាលលើការស្ថាបនា ការធ្វើប្រតិបត្តិការ ការផ្តល់ និងការប្រើប្រាស់ បណ្តាញ និងសេវា ទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន ដូចមានចែង ក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ នស/ រកត/០៣១២/១៧៥ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។
- **តម្លៃដើម (Cost base)**៖ គឺជាតម្លៃដែលបណ្តាប្រតិបត្តិករទូរស័ព្ទ ផ្តល់ជូនបញ្ញត្តិករទូរគមនា-គមន៍កម្ពុជា រៀងរាល់ ៦ខែម្តង សម្រាប់ជាមូលដ្ឋាន ដើម្បីតាមដាន និងត្រួតពិនិត្យអំពីភាពស្មោះត្រង់ ក្នុងការប្រកួតប្រជែង ហើយតម្លៃដើមនេះ ត្រូវបានគណនា ផ្អែកតាមរូបមន្ត ដែល ត្រូវបានកំណត់ដោយសហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ដែលមានឈ្មោះថា Long Run Average Incremental Cost (LRIC) គឺជាតម្លៃគំរូ ឬម៉ូឌែល សម្រាប់ប្រើប្រាស់ក្នុងការរៀបចំបទប្បញ្ញត្តិ ទូរគមនាគមន៍។
- **ការប្រកួតប្រជែងដោយស្មោះត្រង់ (Fair Competition)**៖ គឺជាការប្រកួតប្រជែងមួយ ត្រូវផ្អែក លើមូលដ្ឋានបី រួមមានតម្លៃសេវា គុណភាពសេវា និងការផ្សព្វផ្សាយពាណិជ្ជកម្ម ពុំមានការបន្លំ ឬបំភ័ន្ត ឬរំលោភបទប្បញ្ញត្តិ ឬបទដ្ឋានគតិយុត្តជាធរមាន និងដោយមិនបន្ទាបតម្លៃទាបជាងតម្លៃដើម។
- **ការកំណត់តម្លៃទាបជាងតម្លៃដើម (Predatory Pricing)**៖ គឺជាយុទ្ធសាស្ត្រកំណត់តម្លៃផលិតផល ឬសេវា ក្នុងតម្លៃថោកជាងតម្លៃដើម សំដៅផ្តួលរំលំគូប្រកួតរបស់ខ្លួននៅក្នុងទីផ្សារ ឬជាការបង្កើតនូវរបាំងទប់ស្កាត់ការឈានចូលទៅក្នុងទីផ្សាររបស់គូប្រកួតថ្មី ប្រកបដោយសក្តានុពល។

- ប្រតិបត្តិករ៖ សំដៅលើប្រតិបត្តិទូរស័ព្ទទាំងអស់ ដែលកំពុងប្រកបពាណិជ្ជកិច្ចនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៥.** **តម្លៃសេវាហៅទូរស័ព្ទក្នុងបណ្តាញតែមួយ** ( **ដោយពុំទាន់គិតពីអាករលើតម្លៃបន្ថែម និងអាករពិសេស** )

ចំពោះតម្លៃសេវាហៅក្នុងបណ្តាញទូរស័ព្ទចល័ត ឬអចល័តតែមួយ ប្រតិបត្តិករទាំងអស់មានកាតព្វកិច្ច ដូចខាងក្រោម៖

**ក.** គោរពគោលការណ៍នៃការប្រកួតប្រជែងដោយស្មោះត្រង់ ដែលត្រូវបានណែនាំដោយសហភាពទូរគមនាគមន៍អន្តរជាតិ (ITU) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងការទប់ស្កាត់ការអនុវត្តតម្លៃទាបហួសហេតុជាងតម្លៃដើម (Cost Base/ Long Run Average Incremental Cost) ដែលត្រូវបានវាយតម្លៃដោយបញ្ញត្តិករ។

**ខ.** ផ្តល់ជូនមកបញ្ញត្តិករនូវតម្លៃដើម ដែលត្រូវបានបញ្ជាក់ដោយសវនករឯករាជ្យ ដែលទទួលបានគុណវុឌ្ឍិពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជារៀងរាល់ ៦ខែម្តង គិតចាប់ពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ នេះតទៅ ដើម្បីអនុញ្ញាតឲ្យបញ្ញត្តិករមានមូលដ្ឋានក្នុងការតាមដាន និងត្រួតពិនិត្យអំពីភាពស្មោះត្រង់ក្នុងការប្រកួតប្រជែង។

**ប្រការ ៦.** **តម្លៃសេវាហៅឆ្លងបណ្តាញ តម្លៃតភ្ជាប់បណ្តាញ និងកម្រៃនានា** ( **ដោយពុំទាន់គិតពីអាករលើតម្លៃបន្ថែម និងអាករពិសេស** )

តម្លៃ និងកម្រៃនានាពាក់ព័ន្ធនឹងការហៅឆ្លងប្រព័ន្ធ ព្រមទាំងកាតព្វកិច្ចផ្សេងៗទៀតរបស់ប្រតិបត្តិករ ចំពោះរដ្ឋ នឹងត្រូវរក្សាទុកដដែល ក្នុងកម្រិតដូចមានចែងក្នុងចំណុច ៣ នៃលិខិតលេខ ២០៦៥ សជណ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី រហូតដល់ពេលដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា និងប្រតិបត្តិករទាំងអស់ ពិភាក្សាគ្នាសាជាថ្មី ដើម្បីធ្វើការកែសម្រួលតម្លៃ និងកម្រៃនានាទាំងនោះ។

**ប្រការ ៧.** **ប្រសិទ្ធភាពនៃការអនុវត្ត**

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីណែនាំនេះ ត្រូវទុកជានិរាករណ៍។ សេចក្តីណែនាំនេះ អាចនឹងធ្វើការកែប្រែជាយថាហេតុតាមករណីចាំបាច់ ។

**ប្រការ ៨.    អវសានប្បញ្ញត្តិ**

សមាជិកទី១ សមាជិកទី២ ប្រធានលេខាធិការដ្ឋាន អនុប្រធានលេខាធិការដ្ឋាន ប្រធានអង្គភាព និងមន្ត្រីក្រោមឱវាទបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ព្រមទាំងគ្រប់ប្រតិបត្តិករទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ៕

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែ ៥ ឆ្នាំ២០១៣

**ប្រធាន**

ម៉ូវ ចរិយា

**ចម្លងជូន**:

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

<ដើម្បីជូនជ្រាប>

-ដូចប្រការ (៨)

-គ្រប់ប្រតិបត្តិករ

<ដើម្បីអនុវត្ត>

-ឯកសារកាលប្បវត្តិ